ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខាធិការដ្ឋានរដ្ឋបាលសរុប

# កំណត់ហេតុ

## ស្តីពី ការប្រារព្ធវេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី២ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ថ្ងៃព្រហស្បតិ៍ បួនរោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.សពីរពាន់ប្រាំរយហុកសិបពីរ ត្រូវនឹងថ្ងៃទីសាមសិប ខែសីហា ឆ្នាំពីរពាន់ដប់ប្រាំបី វេលាម៉ោងដប់ប្រាំមួយរសៀល គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដោយមានការសម្របសម្រួលពីអង្គការ ការីតាសកម្ពុជា បានប្រារព្ធវេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី២ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ដោយមានការនិមន្ត និងអញ្ជើញចូលរួមជាកិត្តិយសពី ឯកឧត្តម លោកជំទាវ សមាជិករាជរដ្ឋាភិបាល សមាជិកព្រឹទ្ធសភា មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា សម្តេចសង្ឃទាំងពីរគណៈ សម្តេចសង្ឃព្រះប្រធានលេខាធិការដ្ឋានគណៈសង្ឃនាយក តំណាងសាសនាកាតូលិក ប្រូតេស្តង់ និងឥស្លាមសាសនា ព្រមទាំងថ្នាក់ដឹកនាំក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍជាតិ អន្តរជាតិ សភាពសហព័ន្ធយុវជនកម្ពុជា យុវជនកាយរិទ្ធ យុវជនកាកបាទក្រហម សរុបប្រមាណ ១,៥០០ អង្គ/នាក់។

ជាកិច្ចចាប់ផ្តើម នៃកម្មវិធី **ឯកឧត្តម ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា បានថ្លែងពីចំណាប់អារម្មណ៍ និងស្វាគមន៍ ទៅកាន់វេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី២នេះថា៖ វេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី២ គឺជាពិធីសូត្រធម៌ អធិដ្ឋាន បួងសួង និងបញ្ជូនសារ ដើម្បីចូលរួមចំណែកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់ទម្រង់ រូបភាព និងទាសភាពសម័យទំនើប។ ទោះបីមានការខិតខំប្រឹងប្រែង និងសមិទ្ធិផលជាច្រើនពីសំណាក់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្តី បញ្ហានេះនៅតែបន្តកើតមានឡើងជាច្រើននៅលើសកលលោកទាំងមូល ក្នុងទម្រង់ផ្សេងៗ ដូចជា៖ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ផ្លូវភេទ និងសរីរាង្គជាដើម តាមរបាយការណ៍របស់អង្គការសហប្រជាជាតិ បានឲ្យដឹងថាមានបុរស ស្ត្រី និងកុមាររាប់លាននាក់ បាន និងកំពុងរងគ្រោះដោយសារអំពើជួញដូរ ក្នុងនោះមានប្រទេសកម្ពុជាផងដែរ។

ដើម្បីចូលរួមចំណែកបន្តក្នុងការងារប្រឆាំងអំពើជួញដូរមនុស្ស វេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី២នេះ គឺរៀបចំឡើងក្នុងគោលបំណងសំខាន់ៗ៣ គឺ៖

១-ដើម្បីផ្សព្វផ្សាយបង្កើនការយល់ដឹង នៃអំពើជួញដូរមនុស្ស និងតួនាទីសំខាន់ៗរបស់ថ្នាក់ដឹកនាំទាំងឡាយ ក្នុងការអប់រំប្រជាជន ការការពារ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលុបបំបាត់ទាសភាពសម័យទំនើប។

២-ដើម្បីពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការល្អ រវាងស្ថាប័នពាក់ព័ន្ធ ជាពិសេសស្ថាប័នសាសនា ក្នុងការអប់រំ ផ្សព្វផ្សាយអំពើជួញដូរមនុស្ស និងទាសភាពស័យទំនើប នៅតាមវត្តអារាម ព្រះវិហារ និងតាមពិធីសាសនានានា។

៣-ដើម្បីឲ្យសម្លេង នៃការសូត្រធម៌ អធិដ្ឋាននេះ ផ្តល់នូវក្តីសង្ឃឹមដល់ជនរងគ្រោះ អ្នកដែលរងទុក្ខ ដោយសារអំពើជួញដូរមនុស្ស និងសូមឲ្យពួកគាត់ឆាប់បានទទួលនូវសេរីភាពឡើងវិញ។

**លោក គឹម រតនា** នាយកប្រតិបត្តិ អង្គការការីតាសកម្ពុជា ឡើងថ្លែងចំណាប់អារម្មណ៍ វេទិកាអន្តរសាសនា លើកទី២នេះ ជាការខិតខំប្រឹងប្រែង និងជាស្នាដៃដ៏ប្រសើរ ដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ដឹកនាំសាសនា នៃព្រះរាជាណាចក្រកម្ពុជា អង្គការជាតិ អន្តរជាតិ និងបរិស័ទទាំងអស់រួមកម្លាំងគ្នា តាមជំនឿសាសនារបស់ខ្លួន ដើម្បីបង្កើនការយល់ដឹងអប់រំ ផ្សព្វផ្សាយ សូត្រធម៌ អធិដ្ឋាន និងបញ្ជូនសារ បញ្ឈប់ការជួញដូរមនុស្ស និងទាសភាពបែបទំនើប។

លើសពីការខិតខំប្រឹងប្រែង និងលើសពីសមត្ថភាពដែលមនុស្សអាចធ្វើបាននោះយើងសង្ឃឹមថា តាមរយៈការសូត្រធម៌ អធិដ្ឋាន បួងសួង តាមជំនឿសាសនានីមួយៗសុំពរជ័យពីព្រះជាម្ចាស់ ដើម្បីឲ្យយើងប្រកបដោយកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាញាណ និងសេចក្តីក្លាហានក្នុងការបំពេញកិច្ចការដ៏លំបាកលំបិននេះបន្តទៀត។ តាមរយៈសូត្រធម៌ អធិដ្ឋាន បួងសួង និងបញ្ជូនសារ សាសនានីមួយៗឲ្យស្គាល់បុណ្យ បាប ល្អ និងអាក្រក់។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គជបជ បានឡើងអានរបាយការណ៍សង្ខេប ស្តីពីស្ថានភាពជួញដូរមនុស្សក្នុងវេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី២នេះ ពិធីសូត្រធម៌ អធិដ្ឋាន បួងសួង និងបញ្ជូនសារ គឺដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើប។

បច្ចុប្បន្ននេះ បញ្ហាជួញដូរមនុស្សនៅតែជាប្រធានបទដ៏ក្តៅគគុក ដែលប្រទេសនានាលើពិភពលោកបាន និងកំពុងតែយកចិត្តទុកដាក់ដោះស្រាយប្រយុទ្ធប្រឆាំង និងលុបបំបាត់យ៉ាងសកម្ម។ តាមរបាយការណ៍របស់អង្គការសហប្រជាជាតិ គ្រាន់តែនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក មានជនរងគ្រោះដែលជាបុរស ស្ត្រី យុវវ័យ កុមារ ទារក ប្រមាណជិត១២លាននាក់ ដែលកំពុងតែទទួលរងនូវអំពើរំលោភបំពាន បំបាត់សិទ្ធិជាមនុស្ស និងត្រូវគេកេងប្រវ័ញ្ចយ៉ាងធ្ងន់ធ្ងរ ក្នុងរូបភាពជាទាសភាពសម័យទំនើប។ មនុស្សទាំងអស់ត្រូវបានគេលួងលោម ឆបោក ទាក់ទាញដោយការសន្យា ឬដោយការបង្ខិតបង្ខំ ដើម្បីចាកចេញពីសំណាញ់សុវត្ថិភាព រួចជួបនឹងភាពទ័លច្រក ដែលជាអន្ទាក់ នៃការជួញដូរមនុស្ស ការបង្ខិតបង្ខំ ឲ្យបម្រើសេវាភេទ ឬឲ្យធ្វើការងារធ្ងន់ធ្ងរ ក្នុងស្ថានភាពគ្រោះថ្នាក់ ឬត្រូវបានឃុំឃាំងមិនឲ្យមានទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅ ដើម្បីរំលោភបំពានធ្វើទារុណកម្ម បង្ខំឲ្យប្រើគ្រឿងញៀន ពង្វក់ស្មារតី បង្ខំឲ្យសុំទាន ឬដកហូតសរីរាង្គលក់បន្តទៅតំបន់ផ្សេងទៀត ជនទាំងនេះត្រូវបានកេងប្រវ័ញ្ចយកផលចំណេញពីកម្លាំងពលកម្ម រាងកាយ ខាតបង់ពេលវេលា ធនធាន សុខភាព ដែលមួយចំនួនក្លាយជាជនជរាពិកា បាត់បង់សមត្ថភាពពលកម្ម វិកលចរិក ខ្លះបាត់បង់ជីវិត យ៉ាងអណោចអាធម្ម ដែលមួយចំនួនធំបាត់ដំណឹងមិនទាំងដឹងថារស់នៅទីណាផង។

ដើម្បីបានជ្រាបកាន់តែច្បាស់អំពីអំពើជួញដូរមនុស្ស ខ្ញុំព្រះករុណា សូមគោរពទូលថ្វាយ និងជម្រាបថា តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ អំពើជួញដូរមនុស្សមានធាតុផ្សំ៣៖ ១.សកម្មភាព, ២.មធ្យោបាយ, ៣.គោលបំណង។

**សម្ដេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គជបជ បានមានប្រសាសន៍ថា៖ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ ខ្ញុំមានសេចក្ដីរំភើបរីករាយ ឥតឧបមា និងសូមលំអោនកាយថ្វាយបង្គំព្រះវត្តមានសម្ដេចព្រះមហាសង្ឃរាជាធិបតីទាំងពីរគណៈ សម្ដេចព្រះរាជាគណៈសង្ឃ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមគោរពស្វាគមន៍ចំពោះ វត្តមានគណៈដឹកនាំជាន់ខ្ពស់ នៃឥស្លាមសាសនា សាសនាកាតូលិក គ្រិស្ទបរិស័ទដំណឹងល្អ និងគ្រប់និកាយសាសនា ក្នុងព្រះរាជាណាចក្រកម្ពុជា ឯកឧត្ដម លោកជំទាវ លោក លោកស្រី តាជី យាយជី អង្គការដៃគូជាតិ និងអន្តរជាតិ យុវជន យុវនារីទាំងអស់ ដែលបានមកជួបជុំគ្នាយ៉ាងច្រើនកុះករ ប្រារព្ធពិធីសូត្រធម៌ បួងសួង អធិដ្ឋាន និងបញ្ជូនសារ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើប នាពេលនេះ។ អំពើជួញដូរមនុស្ស ដែលរួមទាំងការលក់ដូរមនុស្ស ការជួញដូរសរីរាង្គមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទលើមនុស្ស បានធ្វើឲ្យមនុស្សគ្រប់ភេទ គ្រប់វ័យ តាំងពីទារក កុមារ យុវវ័យ និងមនុស្សចាស់រាប់លាននាក់ នៅស្ទើរតែគ្រប់ទីកន្លែងក្នុងពិភពលោក រងទុក្ខវេទនា បាត់បង់កិត្តិយស សេចក្ដីថ្លៃថ្នូរ បាត់បង់សិទ្ធិជាមនុស្ស និងសេចក្ដីសុខក្នុងគ្រួសារ ខូចខាតសុខភាពផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ រហូតដល់បាត់បង់អាយុជីវិត ជារៀងរាល់ថ្ងៃ។ នេះជាសោកនាដកម្ម សម្រាប់មនុស្សជាតិ ដែលបង្កដោយជនអគតិ និងឧក្រិដ្ឋជនទាំងឡាយ ដែលព្យាយាមរកគ្រប់វិធី ដើម្បីកេងចំណេញផលប្រយោជន៍លើអ្នកដទៃ ទោះបីជាធ្វើឲ្យគេរងទុក្ខវេទនាផ្លូវកាយ ផ្លូវចិត្ត និងអាយុជីវិតយ៉ាងណាក៏ដោយ ដែលនេះជាអំពើ ឃោរឃៅ អមនុស្សធម៌ គួរឲ្យស្អប់ខ្ពើម ។

ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាល បានខិតខំកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្រាប់បម្រើឲ្យការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងរចនាសម្ព័ន្ធសង្គម ដើម្បីលើកកម្ពស់ស្ថានភាពរស់នៅ របស់ប្រជាពលរដ្ឋគ្រប់រូប រួមទាំងកម្មករ កសិករ អាជីវករ មន្ត្រីរាជការ សិស្សានុសិស្ស ជនពិការ កុមារកំព្រា និងបើកឱកាសទូលំទូលាយ ឲ្យមានជំនឿ សាសនា ការគោរពបូជា គ្រប់បែបយ៉ាង ដែលទាំងនេះ គឺជាភាពសុខដុមរមនាក្នុងសង្គមជាតិ និងអាចកាត់បន្ថយភាពប្រថុយប្រថាន របស់ប្រជាពលរដ្ឋ ដែលប្រឈមនឹងគ្រោះថ្នាក់ ។

វេទិកាអន្តរសាសនានេះ គឺជាសកម្មភាពយុទ្ធនាការពិសេសមួយ ដែលបង្ហាញអំពីភាពសុខដុមរមនា នៃសាសនា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានគោលដៅរួមគ្នា គឺ ការបង្កើតឲ្យមានសេចក្ដីសុខ ផ្លូវកាយ ផ្លូវចិត្ត ដល់មនុស្សផងគ្នា មិនបៀតបៀនគ្នា មិនរំលោភបំពានគ្នា ថែមទាំងបានឯកភាពគ្នា បន្តការអប់រំចិត្ត អប់រំកាយតាមបែបសាសនា រៀងៗខ្លួន ដល់សាសនិក ទាំងឡាយ ឲ្យលើកកម្ពស់សីលធម៌ក្នុងការរស់នៅ និងជួយដាស់តឿនក្រើនរំលឹកគ្នា មិនឲ្យធ្វើនូវអំពើបាប ដោយការកេងប្រវ័ញ្ច រំលោភបំពានលើមនុស្សផងគ្នា ឲ្យរងទុក្ខវេទនា និរាសព្រាត់ប្រាសក្រុមគ្រួសារ ចោលកូនចៅឲ្យកំព្រាអនាថាគ្មានទីពឹងនោះឡើយ។ យើងគប្បីបើកចិត្តឲ្យទូលាយ ធ្វើនូវ

អំពើល្អចំពោះមនុស្សផងគ្នាដោយមិនប្រកាន់ពណ៌សម្បុរ ជំនឿ សាសនា ប្រកបដោយការលះបង់ ជាសទ្ធាក្នុងការជួយឧបត្ថម្ភគាំទ្រ គោរព ឲ្យតម្លៃគ្នា មិនរើសអើង ចំពោះអ្នកដែលមានទុក្ខលំបាក រងគ្រោះ និងកុមារកំព្រា អនាថា។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមសម្តែងនូវការគោរព សរសើរអស់ពីដួងចិត្ត និងសូមគាំទ្រចំពោះវេទិកាអន្តរសាសនានេះ ឲ្យមានជារៀងរហូត ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាគ្រឹះដ៏រឹងមាំ នៃសីលធម៌សង្គម ក្នុងការលើកកម្ពស់គុណតម្លៃ នៃជីវិត គុណធម៌ក្នុងការរស់នៅ ឲ្យមនុស្សទាំងឡាយក្នុងសហគមន៍ និងនៅទូទាំងប្រទេសមានសេចក្តីសុខ សន្តិភាពផ្លូវកាយ ផ្លូវចិត្ត និងភាពសប្បាយរីករាយជានិរន្តរ៍ ។

សាសនាគឺជាឱសថ ដែលព្យាបាលជម្ងឺផ្លូវចិត្ត ជាមាគ៌ាតម្រង់ផ្លូវឲ្យមនុស្សដើរទៅតាមផ្លូវសុចរិត ជាច្បាប់កម្រិតឲ្យមនុស្សជៀសវាងនូវកំហុសក្នុងការកសាងនូវបាបកម្ម និងឧក្រិដ្ឋកម្មនានា ឲ្យមនុស្សចេះរស់នៅដោយថ្លៃថ្នូរមានការគោរពគ្នា និងឲ្យតម្លៃមនុស្សផងគ្នា ដែលទាំងអស់នេះ គឺជាប្រភព នៃភាពសុខដុមរមនាក្នុងសង្គមជាតិយូរអង្វែង ។

ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងនូវអំណរព្រះគុណ និងអំណរគុណ ព្រមជាមួយនឹងការកោតសរសើរដោយស្មោះចំពោះគំនិតផ្តួចផ្តើមរបស់ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អង្គការការីតាសកម្ពុជា និងប្រមុខដឹកនាំសាសនាទាំងបួន ក្នុងការរៀបចំឲ្យមានវេទិកាអន្តរសាសនានេះឡើង និងសូមថ្លែងអំណរគុណចំពោះស្មារតី ចូលរួមគាំទ្រទាំងធនធានថវិកា កម្លាំងកាយចិត្ត របស់ក្រសួង ស្ថាប័ន និងអង្គការដៃគូទាំងអស់ រហូតដល់មានការប្រារព្ធពិធីអន្តរសាសនាថ្នាក់ជាតិ ជាលើកទី២ នេះឡើង និងសូមលើកទឹកចិត្ត ឲ្យបន្តកម្មវិធីនេះជារៀងរាល់ឆ្នាំ ។

ជាថ្មីម្តងទៀត ក្នុងនាម រាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខ្ញុំព្រះករុណាខ្ញុំ សូមឧទ្ទិសបួងសួង ដល់គុណបុណ្យព្រះរតនត្រ័យ បារមី វត្ថុសក្តិសិទ្ធិ ក្នុងលោក ព្រះអាឡោះ ព្រះយេស៊ូគ្រិស្ទ និងព្រះអាទិទេពនៃគ្រប់និកាយសាសនា ដែលទ្រង់បានបង្កើត និងជួយការពារ ថែរក្សាមនុស្សលោក សូមមេត្តាទទួលយកនូវការអធិដ្ឋានរបស់បរិស័ទ នៃសាសនាទាំអស់ ដែលមានឆន្ទៈដាច់ខាត ប្រឆាំងអំពើជួញដូរ រំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់រូបភាពលើមនុស្ស និងសូមបញ្ចប់ឲ្យបាន នូវទោសភាពសម័យទំនើបនេះ ដើម្បីសេចក្តីសុខរបស់ប្រជាជនកម្ពុជា និងមនុស្សជាតិទាំងឡាយតរៀងទៅ ។ សូមរិទ្ធបារមី នៃព្រះជាម្ចាស់ និងទេវៈគ្រប់អង្គ ប្រោសប្រទានពរជ័យ ដល់សម្តេច ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ មេដឹកនាំសាសនា និងសាសនិកគ្រប់រូប ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី ក្មួយៗទាំងអស់ ទទួលបាននូវ ជោគជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការតរៀងទៅ កុំបីអាក់ខានឡើយ ។

បន្ទាប់មក **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានថ្លែងសាររួមក្នុងពិធីសូត្រធម៌ អធិដ្ឋានដែលមានចំនួន៩ចំនុច មានខ្លឹមសារដូចតទៅ៖

*១-អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួញដូរផ្លូវភេទ ជាអំពើបាបយ៉ាងធ្ងន់ធ្ងរ ត្រូវជៀសវាង។*

*២-យើងទាំងអស់គ្នាប្រឆាំងដាច់ខាតចំពោះបទឧក្រិដ្ឋជួញដូរមនុស្ស និងបទឧក្រិដ្ឋដ៏ទៃទៀត។*

៣-សូមគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ជីវភាពកម្មករ កសិករ មន្ត្រីរាជការ ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។

៤-យើងទាំងអស់គ្នា គ្រប់ភេទ គ្រប់វ័យ មិនមែនជាទំនិញសម្រាប់ឲ្យជនល្មើសជួញដូរ ឬកេងប្រវ័ញ្ចឡើយ

៥-យើងខ្ញុំគាំទ្រ និងជំរុញការផ្តន្ទាទោសជនល្មើស ដើម្បីផ្តល់យុត្តិធម៌ជូនជនរងគ្រោះ។

៦-ប្តេជ្ញាពង្រីកការយល់ដឹង អំពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ទៅសហគមន៍យើង ដើម្បីបានរួចផុតភាពរងគ្រោះ។

៧-យើងរួមគ្នាធ្វើអំពើល្អ ជួយថែទាំ និងមិនរើសអើងជនរងគ្រោះដែលមាននៅក្នុងសហគមន៍យើង។

៨-មនុស្សទាំងឡាយ ទោះមានជំនឿសាសនា និងស្ថានភាពខុសគ្នាយ៉ាងណា ក៏នៅតែជាបងប្អូនយើង ដែលត្រូវផ្តល់ការយកចិត្តទុកដាក់ និងអាណិតស្រឡាញ់ដូចៗគ្នា។

៩-សូមគាំទ្រយ៉ាងពេញទំហឹង នូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ សុខដុមនីយកម្មសាសនានៅកម្ពុជា។

ជាចុងបញ្ចប់កម្មវិធី មានពិធីសូត្រធម៌បញ្ជូនសារតាមបែបព្រះពុទ្ធសាសនា ពិធីអធិដ្ឋានបញ្ជូនសារតាមបែបគ្រិស្តបរិស័ទកាតូលិក ពិធីអធិដ្ឋានបញ្ជូនសារតាមបែបគ្រិស្តបរិស័ទដំណឹងល្អ និងពិធីសូត្រធម៌បញ្ជូនសារតាមបែបឥស្លាមសាសនា។ បន្ទាប់មកមានពិធីជម្នុយាត្រាដង្ហែសារដើរតាមផែននីមួយៗចេញមកខាងក្រៅរួមជាមួយការលើកផ្ទាំងសារ និងមានការសូត្រធម៌ជូនពរជ័យដល់គ្រប់ពុទ្ធបរិស័ទ និងសាសនិកគ្រប់និកាយ និងមានការបង្ហោះប៉េងប៉ោងដែលមានភ្ជាប់សារទៅជាមួយផងដែរ។

វេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី២ នៅកម្ពុជា ពិធីសូត្រធម៌ អធិដ្ឋាន និងបញ្ជូនសារ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើប បានបញ្ចប់នៅវេលាម៉ោងដប់ប្រាំមួយ និងសាមសិបនាទីរសៀល ថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រៃលែង ។

ថ្ងៃអង្គារ ២កើត ខែកទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨

**អ្នកធ្វើកំណត់ហេតុ**

(ហត្ថលេខា)

**គោរពជូន**
**លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**
**និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។
ថ្ងៃអង្គារ ២កើត ខែកទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨
ប្រធានលេខាធិការដ្ឋាន

**ឧត្តមសេនីយ៍ឯក. គង់_ពុទ្ធី**

12/09/18